THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០២២

ជូនចំពោះ ក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃ អង្គារ ទី ៨ ខែ វិច្ឆិកា គឺជាថ្ងៃបោះឆ្នោត។ អគារសិក្សាទាំងអស់ លើកលែងតែកន្លែងសម្រាប់បោះឆ្នោត នឹងត្រូវបិទ ហើយនឹងមិនមានថ្នាក់រៀនសម្រាប់សិស្សទេ ដោយសារប្រទេសជាតិយើងចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៃការជ្រើសរើសអ្នកដឹកនាំសម្រាប់ពេលអនាគត។ រដូវកាលបោះឆ្នោតនេះមានការបែកបាក់គ្នាយ៉ាងខ្លាំង បន្ថែមលើភាពអន្ទះអន្ទែង និងភាពតានតឹងដែលយើងទាំងអស់គ្នាកំពុងដោះស្រាយ ដោយសារអំពើហិង្សានៅក្នុងទីក្រុងរបស់យើង ជំងឺរាតត្បាត និងអ្វីៗជាច្រើនទៀត។ ជាក្រសួងអប់រំមួយ ជារឿងសំខាន់ដែលយើងត្រូវធ្វើចំណែករបស់យើងទៅកាន់ភាពសះស្បើយ ដោយគាំទ្រវប្បធម៌នៃសមធម៌ ការដាក់បញ្ចូល និងការគោរពចំពោះសិស្សគ្រប់រូប ក្រុមគ្រួសារ និងសមាជិកបុគ្គលិក។

ក្រសួងអប់រំរបស់យើងមានមោទនភាពតំណាងឱ្យប្រទេសជាតិរបស់យើងដែលមានភាពចម្រុះដ៏អស្ចារ្យ -- ភាពចម្រុះដែលគួរកាន់យក និងអបអរសាទរ។ ទោះបីជាភាពខុសគ្នារបស់យើងអាចធ្វើឱ្យយើងប្រតិកម្មទៅនឹងលទ្ធផលបោះឆ្នោតខុសគ្នាក៏ដោយ សាលា និងការិយាល័យរបស់យើងត្រូវតែមានសុវត្ថិភាពដោយមិនគិតពីលទ្ធផល -- ដោយគ្មានការស្អប់ខ្ពើម ការគំរាមកំហែង ការសម្លុតធ្វើបាប និងការភ័យខ្លាច។ នេះគឺជាទំនួលខុសត្រូវដែលយើងម្នាក់ៗមានចំណែក។

ខ្ញុំជឿអស់ពីចិត្តថា ការនាំឱ្យយុវវ័យចូលរួមជាពលរដ្ឋល្អ អាច ហើយនឹងរៀបចំអនាគតរបស់ប្រទេសជាតិរបស់យើង ទីក្រុងរបស់យើង និងពិភពលោករបស់យើង។ ដូច្នេះហើយ វាជារឿងសំខាន់ដែលអ្នកអប់រំរបស់យើងបង្កើតកន្លែងដែលមានសុវត្ថិភាពសម្រាប់ការពិភាក្សាក្នុងថ្នាក់រៀនដែលសមស្របតាមអាយុ និងមិនលំអៀងដែលអនុញ្ញាតឱ្យសិស្សបង្ហាញខ្លួនពួកគេតាមរបៀបល្អៗ ដែលគ្មានហានិភ័យ។ ហើយសំខាន់ខ្លាំងណាស់ដែលយើងទាំងអស់គ្នាធ្វើជាគំរូនូវរបៀបចូលរួមជាមួយមនុស្សដែលមានទស្សនៈខុសៗគ្នា ក្នុងលក្ខណៈគួរសម និងអត់ឱន។ នេះគឺជាព័ត៌មានដែលមានប្រយោជន៍មួយចំនួន ដែលយើងទាំងអស់គ្នាអាចយកមកប្រើ៖

- វិធីសប្បាយៗ ៦ យ៉ាង ដើម្បីបង្រៀនកូនលោកអ្នកអំពីការបោះឆ្នោត (6 Fun Ways to Teach Your Kids About Voting)
- តោះទៅបោះឆ្នោត! និយាយទៅកាន់ក្មេងអំពីការបោះឆ្នោត (Let’s Vote! Talk to Children About Voting)

- ការិយាល័យទទួលបន្ទុកផ្នែកបោះឆ្នោតសម្រាប់សិស្ស (Civics Election Headquarters for Students)

អាកប្បកិរិយានៃការនិយាយដោយស្អប់ខ្ពើម ការយាយី និងការរើសអើងដែលបន្ទាបតម្លៃអ្នកដទៃមិនអាចទទួលយកបាននៅគ្រប់ទីកន្លែងនៅក្នុងក្រសួងអប់រំរបស់យើង។ ប្រសិនបើលោកអ្នកឃើញ ដឹង ឬជាគំរុយនៃអាកប្បកិរិយាទាំងនេះ សូមរាយការណ៍អំពីឧបទ្ទវហេតុនេះតាមរបៀបមួយ ក្នុងចំណោមនៃរបៀបដូចខាងក្រោមនេះ៖

1. បំពេញលិខិតរាយការណ៍អំពីការសម្លុតធ្វើបាប ការយាយី និងការរើសអើង តាមអ៊ិនធ័រណិត Bullying, Harassment and Discrimination Reporting Form
2. ហៅទូរស័ព្ទតាមខ្សែទូរស័ព្ទបន្ទាន់សម្រាប់ ការសម្លុតធ្វើបាប/ការយាយី លេខ 215-400-SAFE
3. ផ្ញើអ៊ីមែលទៅ មន្ត្រីផ្នែកអនុលោមតាម/អ្នកសម្របសម្រួល Title IX ដោយផ្ទាល់ តាមរយៈ antiharassment@philasd.org

សូមអរគុណចំពោះការធ្វើចំណែករបស់លោកអ្នកដើម្បីបណ្ដុះបណ្ដាលអ្នកត្រិះរិះដែលមានជំនាញច្បាស់លាស់ទទួលយក និងចូលរួមជាមួយពលរដ្ឋ។ សូមកុំភ្លេចទៅ **បោះឆ្នោត** នៅថ្ងៃទី ៨ ខែ វិច្ឆិកា!

ដោយសេចក្ដីស្មោះស្ម័គ្រ



Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា